# មេរៀនទី ១៣: ស្រឡាញ់ខ្មាំងសត្រូវរបស់អ្នក

## លូកា ៦:២៧-៣៨

**គោលបំណង៖** ព្រះចង់ឲ្យយើងស្រឡាញ់មនុស្សគ្រប់គ្នា។

**ខគម្ពីរចងចាំ៖ លូកា ៦:៣១** *“ដែលអ្នករាល់គ្នាចង់ឲ្យគេប្រព្រឹត្តនឹងខ្លួនជាយ៉ាងណា នោះត្រូវតែប្រព្រឹត្តនឹងគេយ៉ាងនោះដែរ។”*

**ការថ្វាយបង្គំសំរាប់គ្រូ៖(សូមអានហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**

ក្នុងពេលដែលយើងគិតពីការស្រឡាញ់ចំពោះខ្មាំងសត្រូវរបស់យើង វាជារឿងសំខាន់ក្នុងការដែលយើងត្រូវអរព្រះគុណដល់ព្រះយេស៊ូវ ដែលបានជួយនាំយើងឱ្យមានទំនាក់ទំនងជាមួយនឹងទ្រង់ ទោះបីជាយើងមិនសមនឹងទទួលបានបានការនោះក៏ដោយ។ **លូកា ៦:៣១** “ដែលអ្នករាល់គ្នាចង់ឲ្យគេប្រព្រឹត្តនឹងខ្លួនជាយ៉ាងណា នោះត្រូវតែប្រព្រឹត្តនឹងគេយ៉ាងនោះដែរ”។ សម្រាប់អ្នកតើរឿងអ្វីដែលអ្នកគិតថា ពិបាកក្នុងការធ្វើតាមបទគម្ពីរនេះណាស់? **លូកា ៦:៣៦** “ដូច្នេះចូរអ្នករាល់គ្នាមានចិត្ត មេត្តាករុណា ដូចជាព្រះវរបិតានៃអ្នក ទ្រង់មានព្រះហឫទ័យមេត្តាករុណាដែរ។” នៅពេលដែលទំនាក់ទំនងរបស់យើងជាមួយព្រះជាម្ចាស់កាន់តែរីកចម្រើន យើងនឹងចង់បង្ហាញសេចក្ដីស្រឡាញ់របស់យើងទៅកាន់ទ្រង់ ដោយការបង្ហាញនូវសេចក្ដីមេត្តាចំពោះអ្នកដទៃផងដែរ។

**ចំណុចសំខាន់៖** ១. ខ្ញុំឲ្យបញ្ញត្តិថ្មី ២. ព្រះអម្ចាស់ទ្រង់ស្ថិតស្ថេរ ៣. ព្រះយើងជាព្រះអស្ចារ្យ

### ១. អធិស្ឋាន *(សូមនាំកុមារអធិស្ឋានបើក)*

### ២. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ៣. ល្បែងកំសាន្ត «ចាប់យកបេះដូង!»



**សម្ភារៈដែលត្រូវការ៖** (សូមមើលរូបភាពនៅទំព័រខាងក្រោមហើយព្រីន) គ្រូកាត់ក្រដាសបេះដូងដែលមានពាក្យថា៖ ខ្ញុំស្រលាញ់ប៉ាម៉ាក់ ខ្ញុំស្រលាញ់បងប្អូន ខ្ញុំស្រលាញ់យាយតា ខ្ញុំស្រលាញ់ពូមីង ខ្ញុំស្រលាញ់មិត្តភក្តិ ខ្ញុំស្រលាញ់ខ្មាំងសត្រូវ។



១. យកបេះដូងទាំងអស់នោះដាក់ក្នុងកន្ត្រក

២. ចែកកុមារជា២ឬ៣ក្រុមតាមចំនួនកុមារតិច ឬ ច្រើន

៣. ជ្រើសរើសកុមារម្នាក់ចេញពីក្រុមនីមួយៗមក ហើយយកក្រមាចងភ្នែករបស់គាត់ដើម្បីឲ្យគាត់មកចាប់បេះដូងនៅក្នុងកន្ត្រក បើតំណាងក្រុមណាចាប់បានពាក្យថាស្រលាញ់ខ្មាំងសត្រូវ យើងឲ្យរង្វាន់តាមអ្វីដែលគ្រូមាន។

៤. បើចាប់បានពាក្យថា ស្រលាញ់យាយតា ស្រលាញ់ពូមីង ស្រលាញ់មិត្តភក្តិ យើងត្រូវពិន័យគាត់ដោយលាបម្សៅ ឬលាបធ្យូង ឬបូតច្រមុះ ឬដើរបង្ហាញម៉ូត។ល។

## ៤. ការណែនាំមេរៀន

សួរកុមារថាតើពួកគេគិតយ៉ាងដូចម្ដេចចំពោះពាក្យដែលសរសេរថា "ខ្ញុំនឹងស្រឡាញ់សត្រូវរបស់ខ្ញុំ" តើប្អូននឹងមានអារម្មណ៍បែបណានៅពេលដែលនរណាម្នាក់លួចរបស់លេងរបស់ប្អូន? ឬនៅពេលដែលនរណាម្នាក់ធ្វើអាក្រក់ដាក់ប្អូន? តើប្អូនចង់អោបពួកគេ និងចង់ឲ្យអំណោយទៅពួកគេដែរឬទេ? ប្រាកដជា "អត់ទេ" ប្អូនប្រាកដជាចង់ឈ្លោះ ឬខឹងពួកគេទាំងនោះទៅវិញទេ។ នៅថ្ងៃនេះព្រះគម្ពីរបានបង្រៀនយើង អំពីអ្វីដែលយើងត្រូវធ្វើចំពោះអ្នកណាម្នាក់មានដែលចិត្តអាក្រក់ ឬធ្វើបាបយើង។ សូមឲ្យយើងបានរៀនអំពីការនោះហើយធ្វើជាកុមារដែលស្ដាប់បង្គាប់ដល់ព្រះជាម្ចាស់!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

សាច់រឿងនៅក្នុងព្រះគម្ពីរថ្ងៃនេះគឺនិយាយអំពី ព្រះយេស៊ូវបានបង្រៀនថា មនុស្សគ្រប់គ្នាត្រូវស្រលាញ់ដល់ខ្មាំងសត្រូវរបស់ខ្លួន។ នៅពេលជនជាតិអ៊ីស្រាអែលឮបែបនេះពួកគេដឹងថា តើខ្មាំងសត្រូវនេះគឺសំដៅទៅលើអ្នកណា។ នៅក្នុងកំឡុងពេលនោះប្រទេសអ៊ីស្រាអែលត្រូវបានគ្រប់គ្រងដោយចក្រភពរ៉ូម ហើយជនជាតិអ៊ីស្រាអែលមិនត្រូវបានពួកទាហានរ៉ូមធ្វើល្អដាក់នោះទេ។ រដ្ឋាភិបាលរ៉ូមបានយកពន្ធពីជនជាតិអ៊ីស្រាអែល ហើយមានពេលខ្លះពួកទាហានទាំងនោះបានធ្វើបាបដល់ជនជាតិអ៊ីស្រាអែលថែមទៀតផង ដើម្បីធ្វើយ៉ាងណាឲ្យពួកគេអាចយកពន្ធបាន។ ដូច្នេះហើយវាជារឿងលំបាកណាស់ ដែលត្រូវឲ្យជនជាតិអ៊ីស្រាអែលយល់ស្របទៅតាមសេចក្ដីបង្រៀនរបស់ព្រះយេស៊ូវឲ្យទៅស្រឡាញ់ដល់ខ្មាំងសត្រូវរបស់ខ្លួននោះ។ តើឲ្យពួកគេស្រឡាញ់ដល់ទាហានរ៉ូមដែលធ្វើបាបពួកគេបានយ៉ាងដូចម្ដេច?

ក្នុងព្រះគម្ពីរ **លូកា ៦:២៧-៣១** ព្រះយេស៊ូវមានបន្ទូលថា "ប៉ុន្តែខ្ញុំប្រាប់អ្នករាល់គ្នា ដែលកំពុងស្តាប់ថា ចូរអ្នករាល់គ្នាស្រឡាញ់ពួកខ្មាំងសត្រូវ ហើយប្រព្រឹត្តល្អនឹងពួកអ្នកដែលស្អប់អ្នករាល់គ្នាវិញ ចូរឲ្យពរដល់អ្នកណាដែលគេប្រទេចផ្ដាសាអ្នក ហើយអធិស្ឋានឲ្យអ្នកណាដែលធ្វើទុក្ខអ្នក ឯអ្នកណាដែលទះកំផ្លៀងអ្នកម្ខាង នោះត្រូវបែរម្ខាងទៅឲ្យគេទៀត ហើយបើអ្នកណាយកអាវវែងរបស់អ្នកនោះកុំឲ្យឃាត់មិនឲ្យគេយកអាវតូចអ្នកផងឡើយ ចូរឲ្យដល់អ្នកណាដែលសូមអ្នក ហើយបើអ្នកណាយករបស់អ្វីផងអ្នកនោះកុំឲ្យទារវិញឡើយ ដែលអ្នករាល់គ្នាចង់ឲ្យគេប្រព្រឹត្តនឹងខ្លួនជាយ៉ាងណា នោះត្រូវតែប្រព្រឹត្តនឹងគេយ៉ាងនោះដែរ។"

តើរឿងនេះស្តាប់ទៅដូចជាអ្វីដែលអ្នកអាចធ្វើវាបានដែរឬទេ? ហេតុអ្វីបានជាយើងត្រូវតែធ្វើបែបហ្នឹង? សម្រាប់ចម្លើយព្រះយេស៊ូវបានពន្យល់នៅក្នុងព្រះគម្ពីរ **លូកា៦:៣២-៣៦** ថា "បើអ្នករាល់គ្នាស្រឡាញ់ តែពួកអ្នកដែលស្រឡាញ់ដល់អ្នក នោះតើមានគុណបំណាច់អ្វី ដ្បិតទាំងមនុស្សមានបាបក៏ស្រឡាញ់ដល់ពួកអ្នកដែលស្រឡាញ់គេដូចគ្នាដែរ។ ហើយបើអ្នករាល់គ្នាប្រព្រឹត្តល្អ ចំពោះតែពួកអ្នកដែលប្រព្រឹត្តល្អនឹងខ្លួនអ្នក នោះតើមានគុណបំណាច់អ្វី ដ្បិតទាំងមនុស្សមានបាបក៏ប្រព្រឹត្តដូច្នោះដែរ។ បើអ្នករាល់គ្នាឲ្យគេខ្ចីដែលសង្ឃឹមនឹងបានវិញ នោះតើមានគុណបំណាច់អ្វី ដ្បិតទាំងមនុស្សមានបាបក៏ឲ្យមនុស្សមានបាបខ្ចីដែរដើម្បីឲ្យបានដូចដើមវិញ។ ចូរស្រឡាញ់ដល់ខ្មាំងសត្រូវរបស់អ្នករាល់គ្នា ឲ្យប្រព្រឹត្តល្អនឹងគេហើយ ឲ្យគេខ្ចីដោយឥតសង្ឃឹមនឹងបានអ្វីមកវិញចុះ នោះអ្នករាល់គ្នានឹងបានរង្វាន់ជាយ៉ាងធំ ហើយនិងធ្វើជាកូននៃព្រះដ៏ខ្ពស់បំផុត ដ្បិតទ្រង់តែងល្អដល់ទាំងមនុស្សអកត្តញ្ញូ និងមនុស្សអាក្រក់ដែរ។ ដូច្នេះចូរអ្នករាល់គ្នាមានចិត្តមេត្តាករុណា ដូចជាព្រះវរបិតានៃអ្នកទ្រង់មានព្រះហឫទ័យមេត្តាករុណាដែរ។"

ព្រះយេស៊ូវសន្យាថា បើសិនជាយើងស្រឡាញ់ដល់អ្នកដែលមិនធ្វើល្អដាក់យើង ដោយមិនរំពឹងនូវរង្វាន់អ្វីទាំងអស់ នោះយើងនឹងទទួលបានរង្វាន់ពីព្រះវិញ! យើងនឹងក្លាយជាកូនរបស់ព្រះដ៏ខ្ពង់ខ្ពស់បំផុត ពីព្រោះព្រះអង្គមានចិត្តសន្តោសចំពោះ "មនុស្សពាល និងមនុស្សទុច្ចរិត"។ បន្ថែមពីលើនេះយើងត្រូវចងចាំថា ព្រះមានសេចក្តីមេត្តាករុណាដល់យើង ហើយទ្រង់ស្រឡាញ់យើងសូម្បីតែពេលយើងធ្វើខុស ច្រើនហើយយើងធ្វើដូចជាខ្មាំងសត្រូវរបស់ទ្រង់ក៏ដោយ។ ការប្រព្រឹត្តិជាមួយអ្នកដទៃដោយក្តីស្រឡាញ់ និងក្តីមេត្តាអាចពិបាកនឹងធ្វើ។ មានតែក្តីស្រឡាញ់របស់ព្រះយេស៊ូវសំរាប់យើងប៉ុណ្ណោះទេ ដែលអាចធ្វើឲ្យយើងស្រឡាញ់អ្នកដទៃតាមផ្លូវទ្រង់បាន។ ពីព្រោះយើងជាកូនរបស់ព្រះ យើងត្រូវជ្រើសរើសផ្លូវរបស់ទ្រង់។ ផ្លូវរបស់ព្រះគឺជាការស្រឡាញ់អ្នកគ្រប់គ្នា ហើយត្រូវធ្វើល្អជាមួយអ្នកគ្រប់គ្នា សូម្បីតែពួកគេបានធ្វើមិនល្អដាក់យើងក៏ដោយ!

## ៦. សំនួរពិភាក្សា

១. ក្នុងសម័យព្រះយេស៊ូវតើអ្នកណាជាសត្រូវរបស់ជនជាតិអ៊ីស្រាអែល? *ជនជាតិរ៉ូម/ទាហ៊ានចក្រភពរ៉ូម*

២. តើហេតុអ្វីបានជាព្រះយេស៊ូវមានបន្ទូលឲ្យយើងស្រឡាញ់ដល់ខ្មាំងសត្រូវរបស់យើង?
*បើយើងស្រឡាញ់សត្រូវរបស់យើង យើងនឹងបានទទួលរង្វាន់ពីព្រះ*

៣. តើអ្វីជាហេតុផលផ្សេងទៀត ដែលថាយើងគួរតែស្រឡាញ់មនុស្សគ្រប់គ្នា? *ពីព្រោះព្រះជាម្ចាស់បានស្រឡាញ់យើង បើទោះបីជាយើងធ្វើខ្លួនដូចជាខ្មាំងសត្រូវរបស់ទ្រង់ក៏ដោយ*

## ៧. ខគម្ពីរចងចាំ លូកា ៦:៣១

## ៨. ហាត្ថកម្ម ជំរើសទី១: "ស្រឡាញ់សត្រូវរបស់ខ្ញុំ"



**សម្ភារៈដែលត្រូវការៈ** កាត់រូបបេះដូងហើយឲ្យកុមារម្នាក់មួយៗ (សូមមើលបេះដូងដែលមាននៅទំព័រខាងក្រោមសំរាប់ហាត្ថកម្មនេះ) ក្រដាសរាងឈើឆ្កាងនៅលើជញ្ជាំង។

១. ធ្វើឈើឆ្កាងធំមួយដោយប្រើក្រដាសបិតនៅលើជញ្ជាំងឲ្យចេញជារាងឈើឆ្កាង។

២.ឲ្យកុមារម្នាក់ៗសរសេរឈ្មោះរបស់ពួកគេនៅលើបេះដូងដែលនិយាយថា"ខ្ញុំនឹងស្រឡាញ់សត្រូវរបស់ខ្ញុំ"។

៣.បន្ទាប់មកបិទភ្នែកកុមារម្នាក់ៗហើយបង្វិលគេឲ្យបាន៥ជុំ មុនពេលដែលពួកគេដើរទៅបិតបេះដូងនៅលើក្រដាសឈើឆ្កាងលើជញ្ជាំង។ បើសិនកុមារលំបាកក្នុងការស្វែងរកឈើឆ្កាង កុមារផ្សេងទៀតអាចបង្ហាញផ្លូវបាន។

៤. ពេលកុមារទាំងអស់បានដល់វេនហើយ ហើយរូបបេះដូងរបស់ពួកគេត្រូវបានបិទជាប់នឹង ឈើឆ្កាង ហើយសូមឲ្យកុមារទាំងអស់ស្រែកឡើងថា «ខ្ញុំនឹងស្រឡាញ់ខ្មាំងសត្រូវ ព្រោះខ្ញុំជាកូនរបស់ព្រះ!»។

៥. ឲ្យរូបបេះដូង១ទៀតឲ្យកុមារយកទៅផ្ទះ។ ប្រាប់កុមារឲ្យសរសេរឈ្មោះនរណាម្នាក់ដែលពួកគេមិនចូលចិត្ត ហើយបិទរូបបេះដូងនោះនៅលើជញ្ជាំងផ្ទះពួកគេហើយឲ្យពួកគេអធិស្ឋានសំរាប់មនុស្សម្នាក់នោះរាល់ថ្ងៃ។

**ជំរើសទី២៖** ផាត់ពណ៌រូបភាពនៅទំព័រខាងក្រោម។

**៩. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១០. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

ខ្ញុំស្រលាញ់ប៉ាម៉ាក់

ខ្ញុំស្រលាញ់បងប្អូន

ខ្ញុំស្រលាញ់យាយតា

ខ្ញុំស្រលាញ់ពូមីង

ខ្ញុំស្រលាញ់មិត្តភក្តិ

ខ្ញុំស្រលាញ់ខ្មាំងសត្រូវ


ខ្ញុំនឹងស្រលាញ់សត្រូវរបស់ខ្ញុំ
ខ្ញុំឈ្មោះ


ខ្ញុំនឹងស្រលាញ់សត្រូវរបស់ខ្ញុំ
ខ្ញុំឈ្មោះ



# ខ្ញុំនឹងស្រលាញ់សត្រូវរបស់ខ្ញុំ